# កិច្ចសំភាសន៍របស់ព្រះតេជគុណព្រះនាម សួន សុវត្ថា

កៈ អ្នកសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកដែលត្រូវសំភាសន៍ព្រះនាម សួន សុវត្ថា

កៈ ករុណាជាដំបូងខ្ញុំករុណាសូមក្រាបថ្វាយបង្គំព្រះគុណម្ចាស់!
អឺ....ថ្ងៃនេះខ្ញុំព្រះករុណាមានឪកាសដើម្បីនឹងបានមកសំភាសន៍ព្រះតេជគុណផ្ទាល់ហើយ(មានសំលេងរំខានពីខាងក្រៅ) ករុណាបានធ្វើការស្ម័គ្រចិត្តនៅខាងគំរោងរបស់សាលា BYU ហាវៃនៅខាងសហរដ្ឋអាមេរិច
ហើយគំរោងរបស់សាលាមួយនឹងគឺគេតម្រូវអោយធ្វើការសំភាសន៍ប្រជាជនកម្ពុជាដែលគាត់មានវ័យចាប់ពី៣៥ឆ្នាំឡើងទៅ(មានសំលេងរំខានពីខាងក្រៅ) អំពីខ្សែជីវិតរបស់គាត់ពង្សប្រវត្តិហើយនឹងបទពិសោធន៍ដែលគាត់ធ្លាប់បានឆ្លងកាត់តាំងពីមុននឹងរហូតមកដល់ឥលូវនឹងថាតើគាត់ធ្លាប់បានឆ្លងកាត់នូវបទពិសោធន៍ជីវិតអីគេខ្លះ
ដើម្បីនឹងចែកចាយទុកទៅដល់កូនចៅជំនាន់ក្រោយទៀតគេបានស្តាប់ពិសេសកូនចៅហើយនឹងអឺ.....នឹងសាច់ញាតិក៏ដូចជាអ្នកដែលព្រះតេជគុណនឹងពួកគាត់បានដឹងអំពីប្រវត្តិរបស់ព្រះតេជគុណបាន (មានសំលងរំខានពីខាងក្រៅ)
អញ្ជឹងថ្ងៃនេះអឺ.....ព្រះករុណាមានឪកាសដែលបានមកធ្វើការសំភាសន៍ព្រះតេជគុណផ្ទាល់តែម្តង អញ្ជឹងតើព្រះតេជគុណអនុញ្ញាតអោយព្រះករុណាធ្វើការ Record សំលេងរបស់ព្រះតេជគុណហើយនឹងយករូបរបស់ព្រះតេជគុណនឹងយកទៅ Post នៅក្នុវេបសាយរបស់ខាងសាលាដែរឬទេព្រះតេជគុណ?

ខៈ ពរញោម!(មានសំលេងរំខានពីខាងក្រៅ)
អត់អីទេបើចំពោះអាត្មាវាអត់មានអីដែលត្រូវថាអឺមិន....លាក់លៀមអីនោះទេ
បើថាអ្វីដែលញោមចង់បាននឹងអាត្មាអាចនឹងចែករំលែកបានទៅតាមអ្វីដែលអាត្មាបានដឹងណាស់!

កៈ ព្រះករុណា!

ខៈ អាចដឹងអាចយល់អាចឆ្លងកាត់ នឹងអត់អីទេអាត្មាអាចចែករំលែកបានណាស់!

កៈ ព្រះករុណា! ព្រះករុណាអញ្ជើងជាដំបូង(មានសំលេងរំខានពីខាងក្រៅ)
ខ្ញុំព្រះករុណាឈ្មោះហេង
សុជីវីគឺជាអ្នកសំភាសន៍ព្រះតេជគុណផ្ទាល់តែម្តង(មានសំលេងរំខានពីខាងក្រៅ)
ហើយថ្ងៃនេះត្រូវនឹងថ្ងៃទី២២ខែកក្កដាឆ្នាំ២០១៨
អញ្ជើងជាដំបូងនៃកិច្ចសំភាសន៍ព្រះករុណាសូមសួរព្រះនាមរបស់ព្រះតេជគុណតើព្រះតេជគុណមានព្រះនាមអ្វីដែរ?

ខៈ អឺ.....ព្រះនាមរបស់អាត្មាព្រះនាម សួន សុវត្ថា ហៅគុណទា
ពរគង់នៅកុដិលេខ៣៥វត្តនាគវ័ន្តសង្កាត់បឹងកក់២ ខណ្ឌទួលគោក នៅរាជនីយភ្នំពេញណាស់!

កៈ ព្រះករុណា!

ខៈ ពរញោម! ហើយអាត្មាគឺជាមេកុដិ....មេកុដិនៅកុដិលេង៣៥នឹងឯងណាស់ញោមមេកុដិ!

កៈ ព្រះករុណា!
ចុះឈ្មោះអឺ....ព្រះនាមរបស់ព្រះតេជគុណមានព្រះនាមហៅក្រៅដែរឬទេព្រះតេជគុណ?
ឬក៏មានតែមួយព្រះនាមនឹងទេ?

ខៈ អឺ.....

កៈ មានព្រះនាមហៅក្រៅទេ?

ខៈ នឹងព្រះនាម សួន សុវត្ថា ហៅគុណទាៗនឹងអ្នកខ្លះហៅគុណទាៗនឹង!

កៈ
អូ....ព្រះករុណាហើយអឺ....ព្រះនាមរបស់ព្រះតេជគុណនឹងត្រូវនឹងអត្តសញ្ញាណប័ណ្ណដែរទេព្រះតេជគុណ? (មានសំលេងរំខានពីខាងក្រៅ)!

ខៈ ហ្អាស់??

កៈ នៅក្នុងអត្ត....អត្តសញ្ញាណប័ណ្ណរបស់ព្រះតេជគុណណាស់ជាផ្លូវការណាស់.....

ខៈ នឹងឈ្មោះនឹង!

កៈ ឈ្មោះនឹងតែម្តង?

ខៈ ពរនឹងហើយញោម!

កៈ ទាំងនាមត្រកូលអីទាំងអស់នឹងម៉ងហ៎ព្រះតេជគុណ?

ខៈ ពរនឹងហើយ!

កៈ ព្រះករុណា!
ហើយទៅកាលពីនៅពីក្មេងព្រះតេជគុណមានឈ្មោះក្រៅហៅផ្សេងពីនឹងដែរឬទេ?

ខៈ ហៅគុណទាៗ ហៅទាៗអញ្ចឹងម៉ងកាលពីនៅក្មេង!

កៈ ព្រះករុណា! ហើយចុះឈ្មោះនឹងអ្នកណាជាអ្នកដាក់អោយព្រះតេជគុណដែរកាលនឹង?

ខៈ អឺ....គឺញោមប្រុសហើយនឹងញោមស្រីជាអ្នកដាក់អោយ(ឪពុកម្តាយរបស់ព្រះតេជគុណ)!

កៈ
គាត់មានបានប្រាប់ព្រះតេជគុណថាព្រះនាមនឹងមានអត្ថន័យយ៉ាងណាដែរឬទេចំពោះព្រះតេជគុណ?

ខៈ
អឺ....ចំពោះចាស់ពីដើមដែលគាត់អឺ....ដាក់ឈ្មោះកូនអឺ...អ្វីមួយនឹងគាត់ច្រើនតែដាក់រើសតាមថ្ងៃហើយចំពោះអាត្មាវិញកើតនៅថ្ងៃអង្គារ អញ្ចឹងបានជាគាត់ដាក់ឈ្មោះអោយអាត្មានឹងថា គង់រៈគា
ដល់តែពេលអាត្មាអឺ....បន្ទាប់ពីអាត្មាធ្លាប់បានឆ្លងកាត់អឺ....ក្មេងវត្តហើយដល់ពេលមកបួសនៅនឹងក៏ដាក់ព្រះនាមគេហៅថា គង្គាៗ
អញ្ចឹងទៅណាស់អោយវាស្រាលបន្តិចណាស់បើហៅថាគាទៅស្តាប់ទៅវាដូចជាដាច់សាច់ពេកហើយទៅក៏កុំអោយវាស្រាលអញ្ចឹងពេកក៏អោយគេហៅថា គង់រៈគា
នឹងនៅពេលដែលហៅទៅវាដូចជាធ្ងន់ពេក!

កៈ អូ....

ខ៖ ហើយដល់ពេលដែលយើងហៅតែគា
អញ្ចឹងនឹងវារៀងស្រាលក៏អោយអឺ....គេហៅថាគង្គារៗអញ្ចឹងនឹងរហូតមកណាស់ញោម!

ក៖ ព្រះករុណា!

ខ៖ ហៅគង្គារ នឹងទើបតែពេលដែលអាត្មាបួសនឹងទេបានគេហៅថាគង្គារនឹង
កាលពីពេលដែលអាត្មាមិនទាន់បួសជាសង្ឃគេហៅថា គា គា អញ្ចឹងណាស់
ដល់តែពេលដែលបួសហើយនឹងបានគេហៅគង្គារ អញ្ចឹងទៅរហូតមក!
(មានសំលេងរំខានពីខាងក្រៅ)!

ក៖ ព្រះករុណា!

ខ៖ ហើយអឺ....ដែលឈ្មោះរបស់អាត្មានៅក្នុងបញ្ជីជាតិនឹងឈ្មោះ សួន សុវត្ថា
(មានសំលេងរំខានពីខាងក្រៅ)ហើយបើពីមុននឹងគេហៅគង្គារៗនឹងហើយឈ្មោះនៅក្នុងសញ្ញាប័ណ្ណណាស់!

ក៖ ព្រះករុណា!

ខ៖ នឹងហើយ!

ក៖
ហើយទៅខ្ញុំព្រះករុណាចង់សួរព្រះតេជគុណថាឆ្នាំនឹងព្រះតេជគុណមានព្រះជន្មប៉ុន្មានព្រះវស្សាហើយព្រះតេចគុណ?

ខ៖ អាត្មា ៤៨ឆ្នាំ ហើយ!

ក៖ ព្រះករុណា! (មានសំលេងរំខានពីខាងក្រៅ)
ហើយទៅព្រះតេជគុណកើតនៅក្នុងថ្ងៃខែឆ្នាំណាដែរព្រះតេជគុណ?

ខ៖ អឺ....ថ្ងៃទី២៧ខែ០៦ឆ្នាំ១៩៧៣ (មានសំលេងរំខានពីខាងក្រៅ)!

ក៖ ព្រះករុណាហើយអឺ.....

ខ៖ ហើយត្រូវនឹងថ្ងៃអង្គារ ទី២៧ ខែ០៦ ឆ្នាំ១៩៧៣!

កៈ ព្រះករុណា! (មានសំលេងរំខានពីខាងក្រៅ)!

ខៈ នឹងហើយ!

កៈ ចុះសំរាប់ថ្ងៃខែចន្ទគតិវិញព្រះតេជគុណៗកើតនៅក្នុងឆ្នាំណាដែរព្រះតេជគុណ?

ខៈ អឺ.....ចំពោះនៅក្នុងចន្ទគតិវានៅក្នុង....ដូចជាអត់ទាន់ចាំទេញោម!

កៈ ដូចជាឆ្នាំសត្វណាស់ព្រះតេជគុណដូចជាឆ្នាំជូត ឆ្លូវ....

ខៈ អូ....អាត្មាកើតនៅក្នុងឆ្នាំថោះ!

កៈ ព្រះករុណា!

ខៈ នឹងហើយឆ្នាំថោះ!

កៈ ចុះទីតាំងកំណើតរបស់ព្រះតេជគុណវិញ ព្រះតេជគុណកើតនៅក្នុងឯណាដែរ?

ខៈ ទីកន្លែងកំណើតនៅនឹងភូមិតាណុក ឃុំសើប ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង!

កៈ ព្រះករុណា! ហើយចុះព្រះតេជគុណមានបងប្អូនប៉ុន្មាននាក់ដែរព្រះតេជគុណ?

ខៈ អឺ....បងប្អូនទាំងអស់នឹងគ្នានឹងមានប្រាំពីរនាក់
ប៉ុន្តែស្លាប់អស់ពីរនាក់ហើយនៅសល់ប្រាំនាក់!

កៈ ព្រះករុណា! ហើយទៅព្រះតេជគុណជាកូនទីប៉ុន្មានដែរព្រះតេជគុណនៅក្នុងគ្រួសារ?

ខៈ
អាត្មាជាកូនទី...បើ...បើនៅប្រាំពីរនាក់អាត្មាជាកូនទីប្រាំប៉ុន្តែដល់ពេលតែនៅតែប្រាំនាក់នឹងអាត្មាជាកូនពីបី!

កៈ ព្រះករុណា!

ខៈ នឹងហើយ!

ក៖
ចុះព្រះតេជគុណមានបងប្អូនដែលនៅសព្វថ្ងៃនឹងដែលពួកគាត់នៅមានជីវិតនឹងគាត់មានឈ្មោះអីខ្លះដែរ? (មានសំលេងរំខានពីខាងក្រៅ)!

ខ៖ អឺ....បងរបស់អាត្មាទីមួយឈ្មោះ សួន សុភាព (មានសំលេងរំខានពីខាងក្រៅ) បងទីពីរឈ្មោះ សួន សុចាន់ ហើយទីបីគឺ អាត្មានឹង អឺ...ទីបួនឈ្មោះ សួន ស្រីមុំ ត្រូវជាប្អូនស្រីហើយនឹងទីប្រាំនឹងឈ្មោះ សួន ស្រីនាង!

ក៖ ព្រះករុណា!
ហើយអឺ....ព្រះតេជគុណមានការចងចាំនៅរឿងអ្វីខ្លះនៅពេលលើកមុនដូចជាការចងចាំជាមួយនឹងបងប្អូនរបស់ព្រះតេជគុណណាស់ព្រះតេជគុណមានចងចាំអីពីពួកគាត់ដែរឬទេ?

ខ៖ អាត្មាអត់ទាន់យល់ពីសំនួរនឹងចង់ៗសួរថាម៉េច?

ក៖
តើព្រះតេជគុណមានចងចាំនូវសាច់រឿងអ្វីខ្លះកាលពីសម័យមុនណាស់កាលពីពេលដែលគុណនៅក្មេងៗតូចៗ ពីបងប្អូន....

ខ៖ ការជីវិតផ្ទាល់ឬក៏យ៉ាងម៉េច?

ក៖ ជីវិតរបស់បងប្អូនរបស់ព្រះតេជគុណ!

ខ៖ អូ....ជីវិតរបស់បងប្អូនហ្អែស?

ក៖ ព្រះករុណា!

ខ៖ អឺ....កាលដែរនៅពីក្មេងពីកុមារភាពអឺ....ដូចជាបើនិយាយពីតួដូចជាបងរបស់អាត្មាឈ្មោះ សួន សុភាព នឹងគាត់ដែលត្រូវជាបងរបស់អាត្មានឹង (មានសំលេងរំខានពីខាងក្រៅ) អឺ....ចំពោះគាត់បើនិយាយពីក្មេងហើយនឹងតលូវនឹងគាត់ៗធ្វើជាគ្រូបង្រៀនណាស់ ចង់និយាយថាជីវិតរបស់គាត់ក៏ដូចជាជីវិតរបស់អាត្មាដែរពីព្រោះអី? ព្រោះតែថាអាត្មាជាប្អូនរបស់គាត់ក្នុងអឺ....ក្នុងគ្រាក្រអង្គាល់ដែលយើងលំបាកតោចយ៉ាក (មានសំលេងរំខានពីខាងក្រៅ) ហើយកាលនឹងជីវិតគឺតស៊ូមិនថាបងរបស់អាត្មា ឬក៏អាត្មាគឺមានការលំបាកខ្លាំង

ហើយបើនិយាយពីជីវិតរបស់អាត្មាវិញគឺវាវែងឆ្ងាយហើយបើនិយាយពីជីវិតរបស់អាត្មានោះអាត្មានឹងអាចនិយាយបានដល់តែនោះវាៗផ្សេងគ្នា(សើច) ចឹងវាៗអត់ដូចគ្នាណាស់ញោម!

កៈ ព្រះករុណា! អឺ....ព្រះតេជគុណចងចាំអីគេខ្លះអាចមានសង្ឃដីការមកព្រះតេជគុណ!

ខៈ
អឺ....ហើយបើនិយាយពីជីវិតរបស់អាត្មាផ្ទាល់វិញអឺ....កាលពីអាត្មានៅជាកុមារភាពនឹងអាត្មារៀនបានតិចណាស់ពរនឹងរៀនបានតិចដោយសារតែកាលនឹងអឺ....ជីវិតដូចថាយើងនៅក្នុងត្រកូលក្រីក្រលំបាកអញ្ចឹងនឹង (មានសំលេងរំខានពីខាងក្រៅ)
ហើយឪពុកម្ដាយនឹងគាត់មិនសូវជាមានការធូរធារទៀត
ហើយជំនាន់យើងឆ្នាំអឺ....៨០ជាងជាជំនាន់ដែលលំបាកព្រោះយើងទើបតែចប់ពីសង្គ្រាមមកណាស់!

កៈ ព្រះករុណា!

ខៈ
ពរអញ្ចឹងវាទើបតែដាច់មកពីប៉ុលពតនឹងថ្មោងថ្មីមកណាស់ហើយទៅជីវិតរបស់គ្រួសារមានការលំបាក (មានសំលេងរំខានពីខាងក្រៅ)
ហើយ....ហើយទៅនៅក្នុងមួយត្រកូលរបស់អាត្មាដែលៗកាលពីអាត្មានៅជាឧបាសកដែលកាលមុននឹងដែលអាត្មានៅជាឧបាសកមិនទាន់បួសនឹងហើយទៅបងរបស់អាត្មានឹងមួយដែលបងរបស់អាត្មាគាត់បានរៀនខ្ពង់ខ្ពស់ជាងគេ
គាត់បានរៀនរហូតដល់បានក្លាយជាគ្រូណាស់តែចំពោះអាត្មាហើយនឹងបងប្អូនក្រោយៗមកទៀតមកគឺថាជីវិតរបស់យើងនឹងក្រីក្រពេកក៏....ក៏ឈប់រៀននឹងឯងទៅ
ហើយអាត្មាឈប់រៀននៅត្រឹមថ្នាក់ទីប្រាំបី
ដល់តែពេលថ្នាក់ទីប្រាំបីនៅក្នុងឆ្នាំ....មើល....ឆ្នាំប៉ុន្មាននឹងអាត្មាភ្លេចឆ្នាំបាត់ទៅហើយប៉ុន្តែគ្រាន់តែថានៅពេលដែលអាត្មាបានទៅបួសនឹងអាត្មាបួសនៅក្នុងអឺ....ភ្លេចទៀតហើយនៅអនុឆ័យយ៉ា អឺ....បានមកបួសៗហើយបានរយៈពេលពីរឆ្នាំនៅក្នុងឆ្នាំពីរពាន់អឺ....១៩៩២
ឆ្នាំ១៩៩២ណាស់ញោម! (មានសំលេងរំខានពីខាងក្រៅ)!

កៈ ព្រះករុណា!

ខ៖ ហើយបួសបានមួយព្រះវស្សាគត់អាត្មាបានចេញទៅរៀននៅវត្តត្រួយអំពិល អឺ...វត្តស្រែ....វត្តស្រះចក អឹម......! វត្តស្លាកែត នៅក្នុងស្រុកកៀនស្វាយខេត្តកណ្តាលឆ្នាំ១៩៩២ រហូតដល់ឆ្នាំ១៩៩៣ (មានសំលេងរំខានពីខាងក្រៅ) បានអាត្មាបោះឆ្នោតជំនាន់អ៊ុនតាក់អញ្ចឹងណាស់!

ក៖ ព្រះករុណា!

ខ៖ នឹងហើយ! (មានសំលេងរំខានពីខាងក្រៅ) អឺ.....ហើយនៅពេលនឹងអាត្មារៀននៅពុទ្ធិកបឋមសិក្សាអឺ...វត្តស្លាកែត ពរបានចេញអីវត្តស្លាកែតនឹងមកបានអាត្មាមកគង់នៅនឹងវត្តជ្រោយអំពិលពរនៅនឹងក្រុសកៀនស្វាយដូចគ្នានឹងហើយបានបន្ទាប់មកទៀតនៅក្នុងឆ្នាំ១៩០០....អឺ....១៩៩៤, ១៩៩៥ បានអាត្មាចេញពីវត្តនឹងបានមកនៅក្នុងវត្តអឺ...ឬស្សីស្រុក!(មានសំលេងរំខានពីខាងក្រៅ)!

ក៖ ព្រះករុណា!

ខ៖ អឺ....ចេញពីឬស្សីស្រុករយះពីរឆ្នាំអ៍បីឆ្នាំ បន្ទាប់ពីរៀនបានរយះពេលបីឆ្នាំនឹងហើយអាត្មាមកគង់នៅនឹងវត្តឬស្សីស្រុកមួយឆ្នាំទាំងអស់នឹងវាបួនឆ្នាំ (មានសំលេងរំខានពីខាងក្រៅ) ចេញពីនឹង ឯងទៅបានអាត្មាទៅនៅនឹងខេត្តតាកែវចំនួនដប់ឆ្នាំ!

ក៖ ព្រះករុណា!

ខ៖ នៅនឹងខេត្តតាកែវណាស់!

ក៖ ព្រះករុណា!

ខ៖ អាត្មាទៅគង់នៅនឹងរយះពេលដប់ឆ្នាំ!

គ៖ និមន្តទៅបាននៅ? (សំលេងរបស់មនុស្សប្រុស)!

ខ៖ កំពុងតែសំភាសន៍ចាំបន្តិចសិនទៅអាត្មាអោយញោមសំភាសន៍បន្តិចសិន! (ព្រះតេជគុណមានសង្ឃដីការជាមួយនឹងអ្នកមកសួរ)! ហើយដល់អញ្ចឹងឯងទៅអឺ....ទៅនៅនឹងខេត្តតាកែវនឹងរយះពេលដប់ឆ្នាំអាត្មាទៅនៅនឹងអឺ.....

នៅក្នុងឆ្នាំ១៩៩៥នឹង ឆ្នាំ១៩៩៥
ហើយបន្ទាប់មកទៀតនឹងបានឆ្នាំ១៩៩៧អាត្មាបានធ្វើជាព្រះចៅអធិការនៅនឹងវត្តក្នុងខេត្តតាកែវនឹងអញ្ចឹងណាស់!

កៈ ព្រះករុណា!

ខៈ
ពរនឹងគឺជាជីវិតរបស់អាត្មាផ្ទាល់ហើយទៅបានអាត្មាចេញពីខេត្តតាកែវនឹងឯងមកបានអាត្មាមកគង់នៅនឹងវត្តអឺ....នៅវត្តព្រៃកប្ញស្សីដូចជានៅនឹងកៀនស្វាយនឹងដែរប៉ុន្តែឥលូវនឹងដូចជាគេកាត់ចូលទៅក្នុងខណ្ឌមានជ័យហើយ
បន្ទាប់ពីនឹងមកបានអាត្មាមកគង់នៅនឹងវត្តនាគវ័ន្តនេះពរ!

កៈ ព្រះករុណា! ព្រះករុណាហើយ (មានសំលេងរំខានពីខាងក្រៅ)
ចុះញោមស្រីដែលត្រូវជាម្តាយរបស់ព្រះតេជគុណនឹងគាត់មាននាមអឺ
....ឈ្មោះអីដែរព្រះតេជគុណ?

ខៈ អឺ....ញោមស្រីរបស់អាត្មាគឺមានឈ្មោះ យ៉ា ធន់! (មានសំលេងរំខានពីខាងក្រៅ)!

កៈ ព្រះករុណា! ហើយចុះញោមប្រុសរបស់ព្រះតេជគុណវិញព្រះតេជគុណ?

ខៈ អឺ....ញោមប្រុសគាត់ឈ្មោះ សឹម សៀម!

កៈ ព្រះករុណាព្រះតេជគុណ! ហើយចុះពួកគាត់នៅក្នុងឆ្នាំអាយុប៉ុន្មានហើយព្រះតេជគុណ?

ខៈ អឺ....ចំពោះញោមស្រី (មានសំលេងរំខានពីខាងក្រៅ)
របស់អាត្មានឹងគាត់មានអាយុ៧៨ឆ្នាំហើយចំពោះញោមប្រុសរបស់អាត្មាវិញនឹងគាត់ស្លាប់បាត់ហើយគាត់ស្លាប់តាំងពីឆ្នាំ ១៩៩៩ ឯណោះពរគាត់ស្លាប់បាត់ហើយណាស់!

កៈ ព្រះករុណា!
ហើយចុះព្រះតេជគុណមាននៅចាំថ្ងៃខែឆ្នាំកំណើតរបស់ញោមប្រុសញោមស្រីរបស់ព្រះតេជគុណដែរឬទេព្រះតេជគុណ?

ខ៖ អត់មានចាំទេញោម!
គ្រាន់តែដឹងញោមស្រីរបស់អាត្មានឹងគាត់កើតនៅក្នុងឆ្នាំរកប៉ុន្តែបើដូចថាគាត់កើតនៅក្នុងមួយពាន់ប្រាំបួនរយប៉ុន្មានដែលគាត់កើតនឹងអានឹងគឺអាត្មាអត់ដឹងទេ!

ក៖ ព្រះករុណា! ចុះគាត់មានស្រុកកំណើតនៅឯណាដែរព្រះតេជគុណមាននៅចាំដែរឬទេ?

ខ៖ ពួកគាត់នៅអឺ....បើញោមស្រីគាត់នៅនឹងភូមិចំបក់ផ្អែម ហើយបើញោមប្រុសវិញនៅភូមិដូនទយ!

ក៖ ព្រះករុណា!

ខ៖ នឹងហើយញោម!

ក៖
ចុះឪពុកអឺ....ញោមស្រីហើយនឹងញោមប្រុសរបស់ព្រះតេជគុណនឹងដែលត្រូវជាអ្នកឪពុកម្តាយរបស់ព្រះតេជគុណនឹងតើពួកគាត់នឹងប្រកបមុខរបរអីដែរដើម្បីនឹងចិញ្ចឹមព្រះតេជគុណនៅពេលដែលព្រះតេជគុណនៅតូចៗណាស់ព្រះតេជគុណគាត់ធ្វើអីដែរ?
(មានសំលេងរំខានពីខាងក្រៅ)!

ខ៖ អឺ.....ញោមប្រុសញោមស្រីរបស់អាត្មាជា គាត់ប្រកបមុខរបរនឹងធ្វើស្រែចំការ!

ក៖ ព្រះករុណា!
ហើយដូចជាការចងចាំចំពោះឪពុកម្តាយរបស់ព្រះតេជគុណនឹងតើព្រះតេជគុណមានការចងចាំអីគេខ្លះចំពោះពួកគាត់?

ខ៖ អាត្មាចងចាំបាន
ប៉ុន្តែដូចថារឿងនឹងយើងវាបានឆ្លងកាត់មករៀងយូរដែរហើយយើងវាចង់ភ្លេចទៅវិញនឹងអស់ខ្លះទៅហើយប៉ុន្តែគ្រាន់តែនៅចងចាំថាអឺគាត់ធ្វើស្រែចំការហើយបន្ទាប់ពីចប់រដូវដែលធ្វើស្រែចំការនឹងអឺ....គាត់ប្រកបមុខរបរធ្វើការនេសាទ!

ក៖ ព្រះករុណា!

ខ៖ ដាក់លាន់ ដាក់មងដាក់អីនឹង!!

កៈ
ចុះព្រះតេជគុណញោមរបស់ព្រះតេជគុណនឹងតើគាត់មានធ្លាប់ប្រាប់ព្រះតេជគុណមកថាយ
តើខ្សែជីវិតរបស់គាត់នឹងធ្លាប់បានឆ្លងកាត់អ្វីខ្លះមកទេ?

ខៈ
អេ....គាត់...គាត់បានប្រាប់មកខ្លះដែរថាគាត់ជីវិតរបស់គាត់នឹងវាអេ...អារឿងខ្សែជីវិតរបស់គាត់នឹងអាត្មា(សើច)
មិនសូវជាចាំប៉ុន្មានទេទាល់តែសួរគាត់វិញបានដឹងអាត្មាដូចជាមិនដឹងច្បាស់ទេញោម(សើច)
ព្រោះអញ្ចេកអាត្មាបួសតាំងពីអាយុ១៧ឆ្នាំមកអញ្ចឹងកាលពីក្មេងៗនឹងមកគាត់អត់ទាន់បាននិយាយពីប្រវត្តិរបស់គាត់នឹងថាយ៉ាងម៉េចៗទេណាស់ញោម!

កៈ ព្រះករុណា!

ខៈ ហើយទៅអាត្មាក៏ចេញផុតពីនឹងឯងមក
ហើយមកដល់ឥលូវនឹងវាចូលជិត២០ឆ្នាំជាងហើយទៅយើងវាអត់ដែលបានដឹងពីប្រវត្តិរបស់គាត់នោះទេណាស់ញោម!

កៈ ព្រះករុណា!
ចុះព្រះតេជគុណអឺ....មានដឹងតែថាអឺ...ឪពុកម្តាយរបស់ព្រះតេជគុណនឹងគាត់គឺជាមនុស្សបែបណាដែរ?

ខៈ
អឺ....ចំពោះញោមប្រុសញោមស្រីរបស់អាត្មាគាត់អត់មានដូចថាចំពោះដូចថាកាយវិការរបស់គាត់គឺគាត់ស្លូតបុត
គាត់ជាមនុស្សទៀងត្រង់គាត់អត់មានអឺ....ដូចថាមើលងាយមើលស្រាលធ្វើអោយបុគ្គលណាមួយស្អប់ខ្ពើមអីនោះទេណាស់ទាក់ទងទៅនឹងបងប្អូនដែលនៅក្នុងភូមិនៅក្នុង....សឹងតែថាមួយឃុំនឹងគឺអ្នកណាក៏អ្នកណាៗក៏ស្រលាញ់រាប់អានគាត់ដែរបើញោមប្រុសជាមនុស្សដូចថាចូលចិត្តនិយាយកំប្លុកកំប្លែងច្រើន!

កៈ ព្រះករុណា!

ខ៖ ហើយនៅក្នុងកំឡុងឆ្នាំ៨០ជាង៩០
នឹងនៅស្រុកយើងនឹងគេហៅថាជំនាន់ដែលគេកែនយកទៅជីកប្រលាយជីកពីអីនឹងហើយគាត់
នឹងគាត់មិនសូវជាហាត់ទេ
គាត់គេអោយនៅអង្គុយតែស្មៀមនិយាយរឿងកំប្លែងអោយគេស្តាប់អញ្ចឹងគាត់ទៅដល់កន្លែង
ណាក៏គាត់អត់ចេះខ្វះញាតិដែរអញ្ចឹងគេស្រលាញ់គេចូលចិត្តគាត់ដូចថាគាត់និយាយរឿងកំប្លែ
ងកំប្លុកកំប្លែងអោយគេស្តាប់អញ្ចឹងទៅណាស់!

ក៖ ព្រះករុណា!

ខ៖ នឹងហើយ!

ក៖ ព្រះករុណា ចង់ដឹងមួយទៀតដែលទាក់ទងទៅនឹងជីដូនជីតារបស់ព្រះតេជគុណវិញ
តើពួកគាត់ទាំងអស់គ្នានឹងមានឈ្មោះអីខ្លះដែរទាំងជីដូនជីតាអឺ.....

ខ៖ អឺ.....

ក៖ សព្វថ្ងៃឬក៏គាត់អនិច្ចកម្មទៅអស់ហើយព្រះតេជគុណ?

ខ៖ គាត់ស្លាប់ទៅអស់ហើយ ពួកគាត់ស្លាប់តាំងពីពេលដែលអាត្មានៅតូចៗ
ឯណោះអាត្មាអត់ទាំងចាំស្គាល់គាត់ផង គាត់អត់......

ក៖ ព្រះតេជគុណអត់ស្គាល់អត់ដឹងអ្វីទាំងអស់ពីគាត់ហ៎ព្រះតេជគុណ?

ខ៖ អាត្មាគ្រាន់តែចាំគាត់មានឈ្មោះថា តាទូន យាយម៉ោង!

ក៖ អ៎.....

ខ៖ ពរនឹងណាស់
ប៉ន្តែគ្រាន់តែថារូបរាងយ៉ាងម៉េចនឹងគឺអាត្មាអត់ទាន់នោះទេព្រោះកាលដែលគាត់ស្លាប់នោះគឺ
អាត្មានៅជាងគេហៅថា៥ឆ្នាំទៅ៦ឆ្នាំ អញ្ចឹងណាស់ពរអាត្មាភ្លេចមុនរបស់ពួកគាត់អស់ហើយ!

ក៖
អញ្ចឹងព្រះតេជគុណក៏មិនមានចងចាំទិដ្ឋភាពនៅពេលដែលពួកគាត់នៅរស់នឹងដែរហ៎ព្រះតេច
គុណ?

ខ៖ អត់ទេញោម!

ក៖ ព្រះករុណា!
អឺ....ទាក់ទងជាមួយនឹងភាសាវិញកាលពីមុននឹងព្រះតេជគុណមានបានធ្លាប់សិក្សានៅឯណាខ្លះដែលហើយព្រះតេជគុណមានចេះភាសានឹងប៉ុន្មានភាសាដែរព្រះតេជគុណ?

ខ៖ អឺ....ញោមភាសាអាត្មាមិនសូវជាចាប់បាននោះទេ អាត្មាចេះតែភាសាបាលីទេ!

ក៖ ព្រះករុណា!

ខ៖ ព្រោះភាសាបាលីនឹងអាត្មារៀនណាស់!

ក៖ អឹម....

ខ៖ ហើយបើភាសាអង់គ្លេសនឹងអាត្មាបានរៀនដែរ តែរៀនទៅវាមិនបានជាចាំណាស់!

ក៖ ព្រះករុណា!

ខ៖ ពរញោមដូចថារៀនទៅវាដូចថាមិនសូវជាចាប់បានទេ រឿងភាសានឹង!

ក៖
ព្រះតេជគុណអញ្ចឹងភាសាអឺ.....ដូចជាបាលីសំស្រ្កឹតនឹងព្រះតេជគុណរៀននៅឯណាព្រះតេជគុណ?

ខ៖ ភាសាបាលីអាត្មារៀននេះ(មានសំលេងរំខានពីខាងក្រៅ)
នៅនឹងស្រុកគៀនស្វាយនឹងទេញោម
នៅនឹងវត្តស្លាកែតនឹងឯងបន្ទាប់ពីវត្តស្លាកែតនឹងមកបានមកវត្តជ្រោយឬស្សីនឹងភាសាបាលីអាត្មារៀននៅនឹង!

ក៖ ព្រះករុណា!
ហើយការសិក្សារបស់ព្រះតេជគុណវិញមានដល់កំរិតណាដែលព្រះតេជគុណតើព្រះតេជគុណឈប់ពីការសិក្សានឹងនៅត្រឹមកំរិតណាដែលព្រះតេជគុណ?

ខ៖ អឺ....បើថាចំពោះពីក្មេងអាត្មារៀនបានត្រឹមថ្នាក់ទីបី
កាលពីដែលអាត្មានៅជាឧបាសកណាស់ញោម!

ក៖ ព្រះករុណា!

ខ៖
ហើយដល់ពេលតែដែលអាត្មាមករៀននៅវត្តស្លាកែនេះហើយនឹងជ្រោយអំពិលនេះបានគេហៅថាពុទ្ធិកសិក្សាថ្នាក់ទីមួយទីពីរទីបីពរនឹងណាស់ ហើយបន្ទាប់ពីឆ្នាំ២០០៨នឹងឯងមកបានអាត្មាបានមករៀននៅនឹងសកលអាត្មារៀននៅសាលាធនធានមនុស្ស(សលកវិទ្យាល័យជាតិគ្រប់គ្រង)!

ក៖ ព្រះករុណា! (មានសំលេងរំខានពីខាងក្រៅ)!

ខ៖ ពរ នឹងអាត្មារៀននៅសាលាធនធានមនុស្ស!

ក៖ ចុះកាលដែលថ្នាក់ទីប្រាំបី នៅអនុវិទ្យាល័យនឹងឈ្មោះសាលាអីដែរព្រះតេជគុណ?

ខ៖ អឺ....អនុវិទ្យាល័យថ្នល់ទទឹង!

ក៖ ព្រះករុណា!

ខ៖ អេ! មិនមែនមិនម៉េចនឹងញោមសួរបឋមសិក្សាមែនទេ? ឬក៏អនុវិទ្យាល័យ?

ក៖ អនុវិទ្យាល័យព្រះតេជគុណ!

ខ៖ អឺ.....អនុវិទ្យាល័យថ្នល់ទទឹង! (ក្រហែម)

ក៖ ព្រះករុណា! ចុះព្រះតេជគុណមានមិត្តភក្តិស្និទស្នាលដែរឬទេ?
ពេលដែលព្រះតេជគុណតាំងពីមុននឹងរហូតមកដល់ឥលូវនឹងណាស់ព្រះតេជគុណ?

ខ៖ អឺ...ពីមុនមកដល់ឥលូវនឹងអាត្មាដូចជាមិនមានមិត្តភក្តិស្និទស្នាលនោះទេ (មានសំលេងរំខានពីខាងក្រៅ)
ព្រោះអីកាលដែររៀននៅបឋមរៀននៅវិទ្យាល័យដូចថាយើងបែកគ្នាយូរឆ្នាំមកហើយដូចថាយើងវាភ្លេចគ្នាអស់ហើយណាស់ហើយបើអាត្មាមករៀននៅនឹងសកលនឹងមាន

ប៉ុន្តែគ្រាន់តែថាឥលូវនឹងយើងវាបែកគ្នាទៅអស់ទៅហើយព្រោះកាលរៀនជំនាន់ទីប្រាំបីនឹងវាមានមិត្តភក្តិប៉ុន្តែឥលូវនឹងយើងវាបែកបាក់គ្នាអស់អ្នកខ្លះគេមានគ្រួសារទៅនៅតាមខេត្តអញ្ចឹងឯងទៅវាអស់រលីងហើយណាស់!

ក៖ ព្រះករុណា!

ខ៖ ហើយទៅវាមានប៉ុន្តែគ្រាន់តែថាវាមិនសូវជាជិតដិតនោះទេ
កាលពីពេលនៅរៀនបានវាជិតដិតអញ្ចឹងណាស់ញោម!

ក៖ ព្រះករុណា!
ចុះព្រះតេជគុណកាលពីពេលនៅរៀននឹងអឺ...មិត្តភក្តិរបស់ព្រះតេជគុណនឹងពួកគាត់មានឈ្មោះអីដែរដូចថាមិត្តភក្តិជិតដិតណាស់?

ខ៖ អឺ.....រៀននៅសកលនឹងមាន ធី ប៊ុនណា!

ក៖ ព្រះករុណា!

ខ៖ ពរ ញោម ធី ប៊ុនណា នឹងជិតដិតដូចថាធ្លាប់ឌុបអាត្មាមកអញ្ចឹងទៅមានអីហើយមាន ពុក សោភា មួយទៀតនឹងហើយ!

ក៖ ព្រះករុណា! ហើយចុះពួកគាត់អឺ....ព្រះតេជគុណមានចងចាំរឿងអីខ្លះពីពួកគាត់នឹង?

ខ៖ មិនចងចាំទេញោម
ព្រោះអីដូចថាយើងទៅរៀននឹងរៀនជាមួយគ្នាដល់ហើយនៅពេលដែលរៀនចប់នឹងយើងក៏បែកគ្នារៀងៗខ្លួនទៅណាស់ យើងវាអត់បាននៅជុំគ្នាទេ!

ក៖ ព្រះករុណា!

ខ៖ ហើយទៅអាត្មាក៏មិនដឹងថាប្រវត្តិរបស់គេនឹងយ៉ាងម៉េចៗនោះទេ!

ក៖ ព្រះករុណា! អឺ....ហើយចុះព្រះតេជគុណមានធ្លាប់ធ្វើស្រែចំការដែរឬទេព្រះតេជគុណ?

ខ៖ ធ្លាប់កាលដែលអាត្មានៅអាយុជាង១០ឆ្នាំ ១៧ឆ្នាំនឹងអាត្មាធ្លាប់ធ្វើ!

ក៖ អញ្ចឹងមានន័យថាកាលពីមុននឹងគ្រួសាររបស់ព្រះតេជគុណនឹងគឺជាកសិករត្រូវទេ?

ខ៖ គឺជាកសិករ ពរញោម!

ក៖ ជាកសិករដែរ!

ខ៖ នឹងហើយញោម!

ក៖ ព្រះករុណា!
អឺ....ព្រះតេជគុណតើព្រះតេជគុណមានធ្លាប់បានធ្វើការងារអីខ្លះនៅក្នុងជីវិតរបស់ព្រះតេជគុណា? មុននឹងចូលធ្វើ...បួសជាអ្នកសាងផ្នួសអញ្ជឹងណាស់?

ខ៖
អឺ....នៅក្នុងជីវិតរបស់អាត្មាកាលពីនៅពីក្មេងមុនពេលដែលមកបួសអាត្មាធ្លាប់ធ្វើស្រែចំការជាមួយនឹងញោមរបស់អាត្មា ហើយក៏ធ្លាប់នេះនេសាទត្រី!

ក៖ ព្រះករុណា!

ខ៖ ដាក់មង ដាក់សន្ទូច ដាក់ទ្រូ ដាក់លាន់អញ្ជឹងឯងទៅ
ហើយមួយទៀតនឹងគឺដាំឈូកជាមួយនឹងញោមប្រុសណាស់នឹងកាលពីអាត្មានៅក្មេងមិនទាន់បានបួសនឹង
នៅក្នុងឆ្នាំ....ហើយដល់ពេលដែលបួសនឹងមកនិយាយអំពីការរៀននឹងនៅពេលដែលអាត្មាទៅបួសរៀននៅនឹងខេត្តតាកែវនឹងអាត្មាបានធ្វើជាព្រះចៅអធិការវត្តគ្រប់គ្រងពុទ្ធបរិស័ទនឹងចំនួនប្រាំភូមិ គ្រប់គ្រងណាស់ជាព្រះចៅអធិការវត្តនឹង!

ក៖ ព្រះករុណា!
ហើយចុះតាំងពីក្មេងមកឥលូវនឹងតើជីវិតរបស់ព្រះតេជគុណនឹងមានការផ្លាស់ប្តូរអីគេខ្លះដែរព្រះតេជគុណា?

ខ៖
អឺ....ជីវិតរបស់អាត្មាកាលពីក្មេងរហូតមកដល់ឥលូវនឹងវាអាចផ្លាស់ប្តូរបានប៉ុន្តែគ្រាន់តែថាកាលពីមិនទាន់បានបួសជីវិតនឹងផ្សេងជីវិតក្មេងអឺ...ដូចថាជីវិតក្មេងស្រុកស្រែណាស់យើងវាអត់ទាន់បានដឹងអីហើយដល់ពេលដែលបានមកបួសនឹងបានដឹងអំពីតម្លៃនៃអ្នកបួសហើយក៏ដឹងគុណអំពីមាតាបិតាហើយបន្ទាប់មកពីនោះក៏អាត្មាបានមកសិក្សាភាសាបាលីក៏យល់ដឹងអំពីអឺ....ទំនៀមទំលាប់នៃភាសាបាលីរបស់យើងនឹងដែលជាភាសារបស់ព្រះពុទ្ធសាសនារបស់យើង

ណាស់ពរ
អឺ....ហើយបន្ទាប់មកទៀតនោះអាត្មាក៏បានក្លាយទៅជាអ្នកគ្រប់គ្រងនៅវត្តមួយក្នុងខេត្តតាកែវនឹងក៏ជាអ្នកគ្រប់គ្រងហើយក៏បានយល់ពីកិច្ចការដែលគេហៅថាការគ្រប់គ្រងនឹងហើយរបស់មនុស្សហើយការគ្រប់គ្រងនេះគឺឃើញថាពិបាកដែរណាស់ញោមគឺថាយើងជាមនុស្សតែម្នាក់ហើយគ្រប់គ្រងមនុស្សមួយវត្តហើយយើងនឹងគឺជាមេគេធំអញ្ចឹងគ្រប់គ្រងនៅក្នុងចង្កោមនឹងវាមានប្រាំភូមិនៅក្នុងនឹងហើយវាមានការលំបាកណាស់
ទាំងការអឺ.....ចង់និយាយថាអារម្មណ៍នឹងទឹកចិត្តរបស់មនុស្សយើងម្នាក់ៗនឹងវាមានផ្សេងៗពីគ្នា ដែលធ្វើមិនងាយនឹងអោយយើងដឹងយល់
ប៉ុន្តែគ្រាន់តែដឹងថាទាំងអស់នឹងគឺយើងអាចគ្រប់គ្រងបានយើងយល់ដូចថាយើងយល់ពីកិច្ចនៃការគ្រប់គ្រងណាស់!

ក៖ ព្រះករុណា!

ខ៖ ពរញោម! ហើយបន្ទាប់មកនឹងទៀតនឹងនៅនឹងនេះក៏អាត្មាមានការគ្រប់គ្រងដែរពរហើយអញ្ចឹងអាត្មាបានឆ្លងកាត់នៃការគ្រប់គ្រងនឹងអាត្មាយល់បន្ទាប់ពីអាត្មាបានអឺ....ចូលសិក្សារៀនសូត្រនឹងក៏មានការយុយល់ដឹងច្រើនដូចថាយើងដឹងអំពីតម្លៃនៃការគ្រប់គ្រងហើយស្គាល់អំពីអ្វីដែលល្អនឹងអាក្រក់!

ក៖ ព្រះករុណា!

ខ៖ ពរញោម!

ក៖ ព្រះករុណា!
ហើយចុះព្រះតេជគុណកាលពីមុននឹងព្រះតេជគុណមានចូលម្ហូបអីគេឬក៏មានល្បែងអ្វីដែលធ្វើអោយព្រះតេជគុណចូលចិត្តទាំងពីតូចមករហូតមកដល់ឥលូវណាស់?

ខ៖
អឺ....បើនិយាយអំពីទំនៀមទំលាប់ដែលហៅថាការចូលចិត្តពីម្ហូបបើនិយាយទៅតាំងពីក្មេងរហូតមកដល់ឥលូវនេះនឹងអាត្មាចូលចិត្តសម្លរបៀបខ្មែរៗណាស់ដូចថាស្រែៗណាស់ដូចជាសម្លរប្រហើរ សម្លរគគូរ
អីអញ្ចឹងទៅឬក៏ស្ងោរជ្រក់អីអញ្ចឹងទៅហើយបន្ទាប់ពីនឹងរឿងសាច់រឿងអីនឹងវាជារឿងធម្មតា

នោះទេប៉ុន្តែគ្រាន់តែចំណង់ចំនូលចិត្តហូបចុកផ្ទាល់គឺអញ្ចឹងពរគឺម្ហូបយើងសាមញ្ញនឹងអញ្ចឹងនឹងមិនទៅពិបាកទេ!

ក៖ ព្រះករុណា! ហើយចុះចំពោះល្បែងលេងកាលដែលព្រះតេជគុណនៅពីតូចៗវិញ?

ខ៖
អឺ....ជំពោះល្បែងលេងកាលពីក្មេងៗនឹងកាលជំនាន់នឹងដូចញោមនឹងប្រហែលជាអត់ស្គាល់តែមើលទៅ ល្បែងនឹងគេហៅលេងមឹក កាលដែលនៅនឹងតូចៗនឹងលេងមឹកណាស់!

ក៖ ព្រះករុណា!

ខ៖ គេដាក់....

ក៖ ធ្លាប់លេងតើព្រះតេជគុណ!

ខ៖ ធ្លាប់លេងដែរហ៎? ហើយនឹងលេងគប់បាញ់ថុយ គប់រង់ កាលពីក្មេងណាស់!

ក៖ ព្រះករុណា!

ខ៖ ដែល.....ដែលលេងបាញ់ថុយដែរឬទេ? អត់ដែលទេអត់ស្គាល់ទេមើលទៅ!

ក៖ ព្រះករុណា!

ខ៖
ពរបាញ់ថុយនឹងគឺគេយកអា....អាកេសអាគុយយើងនឹងអាគុយដែលយើង...យើងយកមកចាប់ទូរទស្សន៍នឹងយកមកមូលៗហើយចោះរន្ធប៉ុននឹងឯងទៅហើយដាក់នៅលើជង្គង់បាញ់កៅស៊ូយកកៅស៊ូបាញ់អឺ....លុយ.....

ក៖ អោយចូល(សើច)!

ខ៖
អត់ទេបាញ់ដូចថាដាក់ៗលុយអញ្ចឹងឯងទៅយើងបាញ់ដាក់នៅលើក្បាលជង្គង់នឹងណាស់បាញ់អោយចំលុយដែលដាក់នឹងតែម្តងហើយនៅពេលដែលយើងបាញ់ចំលុយអញ្ចឹងនឹងលុយនឹ

ងវាខ្វាត់ចេញពីវង់នឹងឯងមកគឺបានយើងឈ្មះហើយអានឹងគេហៅថាលេងបាញ់ថុយ ហើយមើលក្មេងសារក្រោយនឹងអត់ស្គាល់ទេបាញ់ថុយនឹង!

កៈ (សើច) ព្រោះឥលូវនឹងអត់សូវមានអាគុយ!

ខៈ និយាយអត់មានទេឥលូវនឹងគឺល្បែងនឹងគឺអត់តែម្តងអាល្បែងនឹង!

កៈ (សើច)!

ខៈ សូម្បីតែលោតមឹកនឹងក៏កន្លែងខ្លះមានហើយកន្លែងខ្លះនឹងអត់មានដែរឥលូវនឹងណាស់!

កៈ ព្រះករុណា!

ខៈ
ពរបើថាលេងបាញ់ថុយវិញគឺបាត់តែម្តងតាំងពីជំនាន់អាត្មាបើគិតទៅតាំងពីជំនាន់យើងឆ្នាំ៨០ ជាងឯណោះហើយមកដល់ឥលូវនឹងដូចជាចូលនៅក្នុង២០១៨ហើយវាដូចជាអត់មានទេល្បែងនឹងឥលូវនឹង!

កៈ ព្រះករុណា!
ចុះព្រះតេជគុណចំពោះបទចំរៀងវិញព្រះតេជគុណចូលចិត្តស្តាប់ដែរឬទេកាលពីមុននឹង?

ខៈ អឺ....ចំពោះបទចំរៀងវិញនឹងអាត្មាចូលចិត្តស្តាប់បទពីដើមៗដូចជារស់ សិរីសុទ្ធា ស៊ិន ស៊ីសមុតនឹងអីនឹងណាស់ដែលជាបទចំរៀងពីដើមៗ
នឹងបទចំរៀងដែលអាត្មាចូលចិត្តស្តាប់ជាងគេនឹងគឺបទចំរៀងពីដើមនឹងហើយអាត្មាអត់សូវចូលចិត្តទេ
បើដូចបទចំរៀងសម័យឥលូវនឹងវាច្រើនដូចថាវាទៅតាមអារម្មណ៍របស់យើងដូចថាអ្នកខ្លះទៅគេចូលចិត្តស្តាប់បទឥលូវអញ្ចឹងទៅតែបើចំពោះអាត្មវិញអាត្មាចូលចិត្តពីដើមៗ!

កៈ ព្រះករុណា!
ហើយចុះបទអីខ្លះដែលធ្វើអោយព្រះតេជគុណចូលចិត្តស្តាប់ហើយគាំទ្រហើយទៅអ្នកចំរៀងរូបខ្លះអញ្ចឹងណាស់ព្រះតេជគុណ?

ខ៖ និយាយរួមអោយតែបទពីដើមអាត្មាចូលចិត្តសឹងតែទាំងអស់ ស៊ិន ស៊ីសមុត រស់ សិរីសុទ្ធា ប៉ែន រ៉ន អីនឹងដែលជាអ្នកចំរៀងពីដើមៗអញ្ចឹងណាស់!

ក៖ ព្រះករុណា!

ខ៖ ពរញោម!

ក៖
ហើយចុះសមាជិកដែលនៅក្នុងក្រុមគ្រួសាររបស់ព្រះតេជគុណវិញតើមានអ្នកណាដែលគាត់ចេះលេងឧបករណ៍ភ្លេងដែរឬទេ?

ខ៖ អត់មានផងញោម! អត់មានអ្នកចេះលេងទេ!

ក៖ ព្រះករុណា! ហើយចុះផ្ទះរបស់ព្រះតេជគុណមានលក្ខណបែបណាដែរព្រះតេជគុណ?

ខ៖
ផ្ទះរបស់ញោមអាត្មានឹងគឺលក្ខណថាអឺ.....យើងធ្វើរបៀបបុរាណធ្វើអំពីឈើប្រក់ប្រូស៊ីម៉ង់ណាស់ដូចគេថាចាប់អឺ....អឺ?? អ៎! ហោណាំងផ្ទះហោណាំងដែលផ្ទះហោណាំងនឹងវាមានសសរ តែបើផ្ទះកាតាំងអត់សសរកណ្តាលទេ បើផ្ទះហោណាំងនឹងគេមានសសរកណ្តាល!

ក៖ ព្រះករុណា!

ខ៖ នឹងណាស់!

ក៖ អឺ....ព្រះតេជគុណផ្ទះនឹងដែរព្រះតេជគុណបានជួយកសាងឬក៏ជួលគេដែរព្រះតេជគុណ??

ខ៖
អឺ...អានឹងយើងដូចថាប្អូននឹងគេអ្នកធ្វើអញ្ចឹងឯងទៅហើយយើងមានលុយជួលគេអោយមកធ្វើណាស់យើងមិនមែនទៅធ្វើដោយខ្លួនឯងនោះទេ យើងជួលគេធ្វើជួលជាង!

ក៖ ព្រះករុណា! សំភារះធ្វើផ្ទះអីនឹងទិញមកឬក៏.....

ខ៖ ទិញគេយកមកធ្វើញោម!

កៈ
អូ.....ចុះព្រះតេជគុណអ្នកណាគេដែលនៅផ្ទះជាមួយនឹងព្រះតេជគុណនឹងចេះធ្វើផ្ទះដែរឬទេ?

ខៈ អត់មានទេញោម!

កៈ អត់មានទេន៍ព្រះតេជគុណ!
ហើយសំរាប់ជំនាញណាស់ដូចជាអឺ.....ការដូចថានៅក្នុងផ្ទះរបស់ព្រះតេជគុណនឹងថាតើមានអ្នកណាគេដែលគាត់មានជំនាញសិប្បកម្មណាស់ចេះច្នៃរបស់ចេះអីនឹងមានដែរឬទេព្រះតេជគុណ?

ខៈ អឺ....អានឹងដូចជាអត់មានទេប៉ុន្តែគ្រាន់តែថាគាត់ចេះៗដូចថាជាងនឹងជាងលាយស៊ីម៉ង់គាត់ចេះរៀបឥដ្ឋធ្វើឥដ្ឋធ្វើផ្ទះថ្មៗអីនឹងរៀបរបងរៀបសសរអីអញ្ចឹងទៅណាស់នឹងគាត់មាន!
(សំលេងទូរស័ព្ទរោទ៍)!

កៈ ព្រះករុណា!
អឺ....សំរាប់បញ្ហាជីវិតរបស់ព្រះតេជគុណវិញតើព្រះតេជគុណអាចប្រាប់ព្រះករុណាបានដែរទេថាកាលពីជីវិតលើកមុននឹងណាស់ព្រះតេជគុណមានជីវិតលំបាកអីគេខ្លះដែរព្រះតេជគុណ?

ខៈ
អឺ.....ជីវិតកាលពីមុននឹងគឺដូចជាអ្វីដែលអាត្មាប្រាប់ពីខាងដើមថាកាលពីនៅក្មេងៗនឹងគឺមានការលំបាកនៅក្នុងការរស់នៅ ការហុបចុកណាស់
វានៅដូចថាយើងពេលនឹងទើបតែចេញពីសង្គ្រាមកអញ្ចឹង
ហើយដល់ទៅញោមនឹងគាត់មិនសូវនេះហើយអញ្ចឹងទៅការរស់នៅនឹងគឺវាមានការលំបាកទាំងការស្លៀកពាក់ទាំងការហូបចុកទាំងអស់នឹងគ្រួសារមានលំបាកដោយសារតែ(មានសំលេងរំខានពីខាងក្រៅ)
ខ្វះខាតខាងជីវភាពតែបន្ទាប់តែពីរនឹងមកនឹងយើងរៀងគ្រាន់បានថាធូរបន្តិចៗមកតែគ្រាន់តែថាវាមិនពិបាកខ្លាំងណាស់ពរកាលនឹងឆ្លងកាត់នូវការលំបាកខ្លាំងនៅក្នុងជីវភាពរស់នៅនឹង!

កៈ ព្រះករុណា!
ចុះសំរាប់បទពិសោធន៍ល្អៗដែលមាននៅក្នុងជីវិតរបស់ព្រះតេជគុណវិញតើព្រះតេជគុណធ្លាប់មានបទពិសោធន៍ល្អៗអីខ្លះដែរ? (មានសំលេងរំខានពីខាងក្រៅ)!

ខ៖ បទពិសោធន៍ល្អៗនឹងដូចជាគ្មានអីទេ
មាននឹងដូចជាមានទើបតែអាត្មាមកបួសនឹងទេដូចថាអាត្មាមាននូវបទពិសោធន៍មាននូវចំណេះដឹងអីហើយការសិក្សារៀនសូត្រអីនឹងទើបតែមាននឹងពេលដែលអាត្មាមកបួសនឹងទេណាស់(មានសំលេងទូរស័ព្ទរោទ៍)
ហើយចំណែកបទពិសោធន៍របស់អាត្មានឹងដូចថាអត់មានទេ(សើច)
ព្រោះយើងនៅជាលោក(ព្រះសង្ឃ)អញ្ចឹងយើងមិនបានទៅមានបទពិសោធន៍អីច្រើននោះទេ ប៉ុន្តែគ្រាន់តែថាអឺ...មានបទពិសោធន៍ដូចជាថារឿងធម៌អារ្យអីនឹងអាច
យើងឡើងធ្វើធម្មទេសនាអីបានណាស់
យើងណែនាំប្រដៅទៅពុទ្ធបរិស័ទអីនឹងបានអញ្ចឹងណាស់នឹងហើយជាបទពិសោធន៍ដែលអាត្មាអាចនឹងចែករំលែកណាស់
ពរនឹងហើយចែករំលែកដូចថាអ្វីដែលអាត្មាមាននឹងគឺចែករំលែកដូចថាទេសនាប្រដៅញាតិញោមពុទ្ធបរិស័ទអោយស្គាលពីព្រះធម៌អារ្យអោយយល់អំពីគុណទោសបាបបុណ្យអីទាំងអស់នឹងតែប៉ុននឹងឯងទេ
ហើយបើក្រៅតែពីរការងារប៉ុណ្ណឹងគឺវាដូចជាអត់មាននោះទេព្រោះអីអាត្មានៅជាលោក(ព្រះសង្ឃ) អញ្ចឹងដូចថាវាអត់មានអីក្រៅពីនឹងណាស់!

ក៖ ព្រះករុណា!

ខ៖ ពរនឹងហើយញោម!

ក៖
ចុះកាលពីក្មេងមកដល់ពីមុននឹងដែលព្រះតេជគុណមិនទាន់បានបួសជាព្រះសង្ឃនឹងពេលនឹងព្រះតេជគុណមានរឿងអីដែលធ្វើអោយព្រះតេជគុណសប្បាយចិត្តនឹកឃើញដល់រឿងនឹងមកធ្វើអោយព្រះតេជគុណសប្បាយចិត្តតែម្តងណាស់?

ខ៖ រឿងអីគេអញ្ចេះ?? អត់យល់ទេញោម?

ក៖
ដូចជារឿងដែលល្អៗដែលកើតឡើងចំពោះព្រះតេជគុណដែលមានមោទនភាពចំពោះខ្លួនឯងណាស់ដូចថាព្រះតេជគុណអាចធ្វើវាបានណាស់ព្រះតេជគុណមានដែរឬទេ?

ខ៖ អាចធ្វើបានគឺមានតែអាត្មាអាចបំពេញបំណងរបស់ញោមប្រុសគឺអាត្មាមកបួសនឹងឯង!

កៈ ព្រះករុណា!

ខៈ ដូចថាគាត់ចង់អោយអាត្មាបួសអញ្ចឹងទៅណាស់
ពរនឹងអញ្ចឹងហើយក៏អាត្មានឹងមកបួសនឹងឯងមកដើម្បីនឹងបំពេញបំណងរបស់គាត់ដែលគាត់ចង់អោយអាត្មានឹងបួស!

កៈ ដើម្បីសងគុណរបស់គាត់!

ខៈ ពរនឹងហើយដើម្បីសងគុណរបស់គាត់
នៅពេលដែលអាត្មាបានបួសគឺអាត្មារំភើបចិត្តនៅត្រង់នឹង!

កៈ ព្រះករុណា!

ខៈ ដូចថាយើងបានសងគុណរបស់គាត់ ដូចថាគាត់ចង់អោយយើងបួសណាស់!

កៈ ព្រះករុណា!

ខៈ អឹម!

កៈ
អញ្ចឹងជាចុងក្រោយនឹងតើព្រះតេជគុណមានពាក្យពេចន៍អីដើម្បីនឹងផ្តាំផ្ញើរទៅដល់កូនចៅជំនាន់ក្រោយៗទៀត?

ខៈ អាត្មាគ្មានអីទេ
គ្រាន់តែថាអឺ....ផ្តាំផ្ញើរគ្រាន់តែថាអ្វីដែល.....ដែលយើងគឺជាទំពាំងស្នងឬស្សី(មានសំលេងរំខានពីខាងក្រៅ)
ជាទំពាំងស្នងឬស្សីយើងត្រូវតែអឺ....ធ្វើអ្វីមួយនឹងគឺធ្វើអោយល្អតាំងខ្លួនជាពលរដ្ឋល្អណាស់ក្លាយទៅជាពលរដ្ឋដ៏ល្អនៅក្នុងសង្គមធ្វើយ៉ាងណាអោយជៀសផុតពីគ្រឿងញៀនហើយនឹងល្បែង ជាពិសេសក្មេងជំនាន់ក្រោយច្រើនតែផឹកនឹងច្រើនណាស់
ពរផឹកនឹងណាស់ទៅណាក៏ឃើញតែសំបូរផឹកនឹងដៃរតលូវនឹង អោយតែថាទៅណាជួបជុំគ្នាហ៎ដូចថាជួបជុំគ្នាទៅលេងនឹងម្តាយទៅលេងឪពុកនៅតាមខេត្តគេជួបជុំគ្នានឹងគ្មានអីក្រៅតែពីការផឹកនូវសុរានឹងទេ
អញ្ចឹងអាត្មាគ្រាន់តែសូមសំណូមពរថាបើអាចកាត់បន្ថយបានក៏កាត់បន្ថយនឹងទៅពររឿងនឹងមួ

យសំខាន់ណាស់ហើយនឹងរឿងមួយទៀតនឹងគឺរឿងគ្រឿងញៀនណាស់យើងត្រូវតែជៀសអោយផុតពីគ្រឿងញៀនព្រោះអីអានឹងវា...វាធ្វើអោយតម្លៃខ្លួនរបស់យើងនឹងវាធ្លាក់ចុះហើយទៅប្រទេសជាតិរបស់យើងនឹងធ្លាក់ចុះដោយសារអីដោយសារតែមានអ្នកដែលសេពគ្រឿងញៀននឹងច្រើន
អញ្ចឹងណាស់នឹងហើយអាត្មាគ្រាន់តែថាចង់ផ្តាំផ្ញើរតែប៉ុណ្ណឹងហើយធម្មតាបើយើងជាកូន....កូនចៅដ៏ល្អត្រូវធ្វើយ៉ាងណាអឺ....ចេះថៃរក្សាសំខាន់គឺខ្លួនយើងគេថាស្រលាញ់អ្វីមិនស្មើរនឹងស្រលាញ់ខ្លួនទេណាស់
អើ.....បើថាចេះស្រលាញ់ខ្លួនហើយយើងត្រូវចេះធ្វើខ្លួនអោយវាល្អចេះខិតខំប្រឹងប្រែងសិក្សារៀនសូត្រទៅដើម្បីនឹងទ្រទ្រង់អនាគត់របស់ខ្លួនឯងនឹងផងនឹងដើម្បីជាសសរទ្រូងប្រទេសជាតិនឹងឯងផង(មានសំលេងរំខានពីខាងក្រៅ) នឹងហើយពរអាត្មាសូមធ្វើការសំណូមពរតែប៉ុណ្ណឹង!

កៈ ព្រះករុណា!

ខៈ ពរញោម!

កៈ អញ្ចឹងជាចុងក្រោយតើព្រះករុណាអាចនឹងធ្វើការ Post សំលេងរបស់ព្រះតេជគុណហើយនឹងរូបថតរបស់ព្រះតេជគុណសំរាប់ការសំភាសន៍ថ្ងៃនេះនៅក្នុងវេបសាយរបស់សាលា BYU នៅសហរដ្ឋអាមេរិចដែរឬទេព្រះតេជគុណ??

ខៈ អឺ....ចំពោះបញ្ហានឹងវាមិនអីទេដូចថាយើងមិននេះទេ ហើយអាត្មាក៏វាត្រេកអរដែរដែលបានសំភាសន៍អញ្ចឹងទៅក៏ជាបទពិសោធន៍មួយ បានន័យថាជាកិច្ចការមួយដើម្បីនឹងធ្វើការចែករំលែកណាស់!

កៈ ព្រះករុណា!

ខៈ ហើយនឹងអឺ.....ប្រជាពលរដ្ឋទូទៅអោយបានស្តាប់បានយល់ពរ ពីអ្វីដែលអាត្មាមានក៏ដូចជាអ្វីដែលអាត្មាបាននិយាយទៅនឹង ហើយអាត្មាក៏សូមធ្វើការអភ័យទោសផងដែរក្រែងលមានការឆ្លោះឆ្លោយអីនឹង ព្រោះនេះមិនបានរៀបចំខ្លួនហើយក៏មិនបានដឹងមុនដែរណាស់!

កៈ ព្រះករុណាព្រះតេជគុណ!(សើច)!

ខៈ ពរហើយទៅមកនៅៗអញ្ចឹងហើយទៅនិយាយទៅតាមអ្វីដែលនឹកឃើញ(សើច)!

កៈ ព្រះករុណា.....

ខៈ ក៏បាន......

កៈ ខ្ញុំព្រះករុណាក៏ត្រូវសូមទោសដែរព្រោះខ្ញុំព្រះករុណាមកនៅៗដែរ(សើច) អត់សូវមានពេលដែលនឹងព្រះតេជគុណ!

ខៈ ពរដល់អញ្ចឹងទៅនិយាយវាមានខុសខ្លះត្រូវខ្លះប៉ុន្តែក៏សូមធ្វើការសូមអភ័យទោសផង ហើយទាំងអស់នេះគឺថាអ្វីដែលអាត្មាមានហើយទៅអាត្មាក៏និយាយទៅដោយត្រង់ៗអត់មានការលាក់លៀមអីនោះទេ!

កៈ ព្រះករុណា!

ខៈ នឹងហើយពរ ហើយក៏សូមអរគុណច្រើនប្អូនស្រីដែលបានមកធ្វើការសំភាសន៏ណាស់!

កៈ ព្រះករុណា!

ខៈ នឹងហើយនឹងអរគុណច្រើនញោម សុខសប្បាយ!

កៈ ព្រះករុណាព្រះតេជគុណសូមអរគុណ!